យើងខ្ញុំក៏មានមោទនភាព អំពីការអភិវឌ្ឍន៍ដ៏ឆាប់រហ័ស និងឃើញមានប្រជាជនខ្មែរឧបត្ថម្ភគាំទ្រដល់ប្រជាជនខ្មែរដូចគ្នា ក្នុងការផ្តល់នូវសេវាកម្មព្យាបាល និងថែទាំដែលប្រកបដោយគុណភាពដល់កូនចៅជំនាន់ក្រោយ ។

ទោះជាយ៉ាងនេះក្តី ក៏មានប្រជាជនខ្មែរជាច្រើននាក់ទៀត ដែលមិនអាចមានលទ្ធភាពគ្រប់គ្រាន់ ដូច្នេះមន្ទីរពេទ្យកុមារអង្គរសូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរទាំងអស់បង្កើនការជួយឧបត្ថម្ភគាំទ្រដល់ប្រជាពលរដ្ឋខ្មែរដូចគ្នា ។

មានតែយើងជាខ្មែរ ដែលអាចជួយធ្វើឲ្យបេសកកម្មរបស់មន្ទីរពេទ្យកុមារអង្គរសម្រេចដល់គោលដៅតាមរយៈទឹកចិត្តដ៏សប្បុរសបរិច្ចាគធនធាន ដើម្បីផ្គត់ផ្គង់លើការចំណាយដូចជាថ្នាំពេទ្យ សម្ភារៈបរិក្ខាពេទ្យ និងការពិនិត្យព្យាបាល ដល់កុមារនៅមន្ទីរពេទ្យកុមារអង្គរ ដោយឥតគិតថ្លៃ ។



ANGKOR HOSPITAL FOR CHILDREN

## ដើម្បីស្វែងយល់អោយបានច្បាស់អំពីមន្ទីរពេទ្យកុមារអង្គរ (មន្ទីរពេទ្យបេះដូង)

សូមទស្សនាមជ្ឈមណ្ឌលព័ត៌មាន
របស់មន្ទីរពេទ្យកុមារអង្គរ (Friends Center)
ផ្លូវទេព វង្ស និងផ្លូវអ៊ុំ ឆាយ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប
(ជិតផ្សារកណ្តាល និង វិទ្យាល័យ ១០ មករា ១៩៧៩)

ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ៖ ៨ព្រឹក - ៥ល្ងាច ថ្ងៃសៅរ៍៖ ៨ព្រឹក - ១២ថ្ងៃត្រង់
រសៀលថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និង ថ្ងៃបុណ្យជាតិ៖ ត្រូវធ្វើការណាត់ជួបជាមុន ។
ឬ ទំនាក់ទំនងមកកាន់ ប្រអប់សំបុត្រលេខ 50 ខេត្តសៀមរាប
ទូរស័ព្ទ: (855) 63 963 409 ទូរសារ: (855) 63 760 452
អ៊ីម៉ែល: ahc@angkorhospital.org
គេហទំព័រ: www.angkorhospital.org

## សូមបរិច្ចាគដល់មន្ទីរពេទ្យកុមារអង្គរតាមរយៈគេហទំព័រ៖

https://angkorhospital.org/support/donations/ ឬ តាមរយៈកុងគណនី
មន្ទីរពេទ្យកុមារអង្គរ ធនាគារ ANZ Royal សាខាខេត្តសៀមរាប
Account Name: Angkor Hospital for Children
Account No.: 2554661




ANGKOR HOSPITAL FOR CHILDREN

# មន្ទីរពេទ្យកុមារអង្គរ

ការព្យាបាល - ការអប់រំបណ្តុះបណ្តាល - ការការពារ



គេហទំព័រ AngkorHospital.org




ANGKOR HOSPITAL FOR CHILDREN

# មន្ទីរពេទ្យកុមារអង្គរ




- មន្ទីរពេទ្យកុមារអង្គរ គឺជាមន្ទីរពេទ្យកុមារដែលផ្តល់ការពិនិត្យព្យាបាល និងថែទាំប្រកបដោយគុណភាព និងឥតគិតថ្លៃដល់កុមារក្នុងតំបន់សៀមរាប នៃព្រះរាជាណាចក្រកម្ពុជា ។

- ប្រជាជនក្នុងតំបន់នេះ ភាគច្រើនហៅមន្ទីរពេទ្យកុមារអង្គរនេះថាជា មន្ទីរពេទ្យបេះដូង ឬមន្ទីរពេទ្យជប៉ុន ។

- មន្ទីរពេទ្យកុមារអង្គរ គឺជាមន្ទីរពេទ្យដែលមានកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិ-បាលកម្ពុជា ជាក់ស្តែងមន្ទីរពេទ្យខេត្តសៀមរាប បានប្រើប្រាស់មន្ទីរពេទ្យកុមារអង្គរជាផ្នែកជំងឺកុមារ និងបានបញ្ជូនកុមារមានជំងឺមកកាន់ទីនេះ ។

- មន្ទីរពេទ្យកុមារអង្គរ បានផ្តល់សេវាពិនិត្យព្យាបាល និងថែទាំ ដល់កុមារមានជំងឺអាយុពី ០ ដល់ ១៦ ឆ្នាំមកពីបណ្តាខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ ១៩៩៩ ហើយជាមធ្យមមានកុមារប្រមាណជាង៥០០នាក់មកទទួលការពិនិត្យព្យាបាល និងថែទាំនៅមន្ទីរពេទ្យកុមារអង្គរជារៀងរាល់ថ្ងៃ ។

- ភាគច្រើនកុមារមានជំងឺដែលអាចការពារបានដូចជា ជំងឺរលាកផ្លូវដង្ហើម ជំងឺរាគរូស ជំងឺកង្វះវីតាមីនជំងឺគ្រុនឈាមជំងឺគ្រុនចាញ់ ជំងឺកង្វះអាហារូបត្ថម្ភជាដើម ។ល។

- មន្ទីរពេទ្យកុមារអង្គរ ក៏ជាមន្ទីរពេទ្យបណ្តុះបណ្តាលបន្តដែរ ដែលបានធ្វើការបណ្តុះបណ្តាលដល់វេជ្ជបណ្ឌិតរាប់រយនាក់ និង គិលានុបដ្ឋាក-យិការាប់ពាន់នាក់ ។

- មន្ទីរពេទ្យកុមារអង្គរ មានផ្តល់សេវាកម្មជាច្រើនដូចជា សេវាពិគ្រោះជំងឺក្រៅសេវាសម្រាកពេទ្យ សេវាសង្គ្រោះបន្ទាន់២៤ ម៉ោង វះកាត់តូចធំគ្រប់ប្រភេទរួមទាំងវះកាត់ភ្នែក និងបេះដូង ពិនិត្យព្យាបាល និងថែទាំសុខភាពមាត់ធ្មេញសេវាអប់រំអំពីការការពារសុខភាព នៅតាមសហគមន៍ និងសេវាព្យាបាលជំងឺអេសដ៍ព្រមទាំងសេវាកម្មជាច្រើនផ្សេងទៀត ។

- មន្ទីរពេទ្យកុមារអង្គរ បានធ្វើការបង្កើតពិធីសារព្យាបាល(Medical Protocols) សម្រាប់វេជ្ជបណ្ឌិត និង ពិធិសារថែទាំ(Nursing Protocols) សម្រាប់គិលានុបដ្ឋាក-យិកាប្រើប្រាស់ក្នុងមន្ទីរពេទ្យ ។

- ក្រសួងសុខាភិបាល ក៏បានប្រើប្រាស់ពិធីសារទាំងនោះសម្រាប់ផ្នែកជំងឺកុមារនៅមន្ទីរពេទ្យដ៏ទៃទៀត នៅទូទាំងប្រទេសកម្ពុជា ។

- មន្ទីរពេទ្យកុមារអង្គរ មានបុគ្គលិកទាំងអស់ចំនួន ៣៤៣ នាក់ ហើយ ៩៩ភាគរយ គឺជាជនជាតិខ្មែរ ។ យើងមានមោទនភាពផ្តល់សេវាកម្មពិនិត្យព្យាបាលនិងថែទាំដល់កុមារកម្ពុជាដោយឥតគិតថ្លៃ ។

- មន្ទីរពេទ្យកុមារអង្គរ បានទទួលការឧបត្ថម្ភពីប្រជាជនកម្ពុជា អាមេរិក ជប៉ុន អង់គ្លេស អ៊ីតាលី អាឡឺម៉ង់ បារាំងកាណាដា កូរ៉េ សិង្ហបុរី ហុងកុង និងប្រទេសជាច្រើនទៀត ។







*** រូបថតទាំងអស់នេះថតដោយ
ជាងថតរូប Karl Grobl និង Daniel Rothenberg ។